# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
3

**រដ្ឋបាលរាជធានីភ្នំពេញ**
r2s

ថ្ងៃអង្គារ ១៣រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១ ខែមីនា ឆ្នាំ២០២២

# ជំនួយស្មារតី

**របស់ឯកឧត្តម ម៉ប់ សារិន ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ សម្រាប់ថ្លែងក្នុង**
**សន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានសង្កាត់ និងទិសដៅការងារបន្តរបស់រដ្ឋបាលរាជធានីភ្នំពេញ"**
r2s

**ជាបឋម** !

- *ខ្ញុំព្រះករុណាខ្ញុំ សូមលំឱនកាយក្រាបថ្វាយបង្គំ **សម្តេចព្រះសង្ឃនាយកទាំងពីរគណៈ** ព្រមទាំងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ !*
- *សូមក្រាបថ្វាយបង្គំ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី និង សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !*
- *សូមគោរព **សម្តេចប្រធានព្រឹទ្ធសភា** និង **សម្តេចប្រធានរដ្ឋសភា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ !*
- *សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជាទីគោរពដ៏ខ្ពង់ខ្ពស់ !*
- *សូមគោរព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !*
- *សូមគោរព សម្តេច ទ្រង់ ឯកឧត្តម-លោកជំទាវ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ជាទីគោរព !*
- *សូមគោរព ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល និងសហការី !*
- *សូមគោរព ឯកឧត្តម-លោកជំទាវ លោក-លោកស្រី មន្ត្រីរាជការ កងកម្លាំង បងប្អូនអ្នកសារព័ត៌មាន ប្រជាពលរដ្ឋ និងទស្សនិកជនដែលកំពុងទស្សនាការផ្សាយបន្តផ្ទាល់ទាំងអស់ ជាទីស្រលាញ់ដ៏ជ្រាលជ្រៅបំផុត !*

**១-** ថ្ងៃនេះ ក្នុងនាមក្រុមប្រឹក្សារាជធានីភ្នំពេញ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំបាទសូមសម្តែងនូវសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានចូលរួមក្នុងសន្និសីទសារព័ត៌មាន ក្រោមប្រធានបទស្តីពី **"វឌ្ឍនភាពមូលដ្ឋានសង្កាត់ និងទិសដៅការងារបន្តរបស់រដ្ឋបាលរាជធានីភ្នំពេញ"** ដែលមានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ជាអ្នកសម្របសម្រួលរៀបចំ និងមានការអញ្ជើញចូលរួមពីបងប្អូនអ្នកសារព័ត៌មានដ៏ច្រើនកុះករ នាពេលនេះ។

**២-** ជាមួយគ្នានេះ ខ្ញុំបាទក៏សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម ផៃ ស៊ីផាន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងសហការី** លោក-លោកស្រី អ្នកសារព័ត៌មាន ដែលបានផ្តួចផ្តើមរៀបចំ និងអនុញ្ញាតឱ្យគណៈប្រតិភូរដ្ឋបាលរាជធានីភ្នំពេញ មានឱកាសចូលរួមធ្វើសន្និសីទសារព័ត៌មាន ដើម្បីជម្រាបជូនសាធារណៈជនអំពី **"ភាពរីកចម្រើនរបស់មូលដ្ឋានសង្កាត់ *និយាយដោយឡែក និងនិយាយជារួម* ក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានីភ្នំពេញ"** ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ

និងគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងការចង្អុលបង្ហាញជាប់ជាប្រចាំរបស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នាពេលនេះ។

**៣-** ជាការពិតណាស់ ក្រោមម្លប់នៃ "**សន្តិភាព**" និងការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជា** បានដាក់ចេញនូវទស្សនទានផ្នែកនយោបាយយ៉ាងមោះមុត ចំពោះការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយមានជំនឿជឿជាក់យ៉ាងខ្លាំងចំពោះតួនាទី-ភារកិច្ចដ៏សំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ប្រកបដោយសមធម៌ សំដៅលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រយ៉ាងពិតប្រាកដ។

**៤-** ជាក់ស្តែង ផ្តើមចេញពីឆន្ទៈ និងទំនុកចិត្តទាំងនេះ ក្នុងអំឡុងពេលជិត **០២** ទសវត្សរ៍កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជា បានជំរុញ និងគាំទ្រយ៉ាងសកម្មដល់ការរៀបចំ និងការអនុវត្តកម្មវិធីជាតិជាបន្តបន្ទាប់ ដោយចាប់ផ្តើមពីការធ្វើកំណែទម្រង់នៅថ្នាក់ឃុំ-សង្កាត់ នៅ**ឆ្នាំ២០០២** និងនៅថ្នាក់រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ នៅ**ឆ្នាំ២០០៩** នាំឱ្យមានការវិវឌ្ឍទៅមុខជាលំដាប់ និងទទួលបានសមិទ្ធផលសំខាន់ៗជាបន្តបន្ទាប់។

**៥-** យ៉ាងណាមិញ តាមរយៈការអនុវត្តដោយជោគជ័យ នូវផែនការអនុវត្ត **០៣ ឆ្នាំ** ដំណាក់កាលដំបូង "**ផអ៣ ទី១**" និងការបន្តអនុវត្ត "**ផអ៣ ទី២**" នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាបណ្តើរៗ **រដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌទាំង១៤ និងរដ្ឋបាលសង្កាត់ទាំង១០៥** កាន់តែត្រូវបានលើកកម្ពស់ស្វ័យភាព ពង្រឹងការទទួលខុសត្រូវ និងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដែលបានឆ្លុះបញ្ចាំង និងរំលេចឱ្យឃើញតាមរយៈ **ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ** និង**កម្មវិធីវិនិយោគបីឆ្នាំរំកិល សម្រាប់អាណត្តិក្រុមប្រឹក្សា នៃរដ្ឋបាលថ្នាក់នីមួយៗ** ដែលបានកើតចេញពីការបោះឆ្នោតសកល និងអសកលយ៉ាងទៀងទាត់ នៅថ្នាក់ក្រោមជាតិ។

*៦- ជាកិច្ចបន្ត ដោយហេតុថា កម្មវិធីនេះជាសន្និសីទសារព័ត៌មាន និងមានពេលវេលាកំណត់ ដូច្នេះ ខ្ញុំបាទសូមអនុញ្ញាតគោរពរាយការណ៍ជូន អំពីសមាសភាពគណៈប្រតិភូរដ្ឋបាលរាជធានីភ្នំពេញ ដែលមានវត្តមានក្នុងឱកាសនេះ និងសូមចាប់ផ្តើមលើកយកមកបង្ហាញអំពីវឌ្ឍនភាព និងទិសដៅការងារសំខាន់ៗ របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ ព្រមទាំងយន្តការនៃការអនុវត្តការងាររបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់មូលដ្ឋានសង្កាត់ ក្នុងរាជធានីភ្នំពេញ ដែលមានខ្លឹមសារសង្ខេប ដូចតទៅ៖*

## I- អំពីសមាសភាពគណៈប្រតិភូរដ្ឋបាលរាជធានីភ្នំពេញ

សមាសភាពគណៈប្រតិភូរដ្ឋបាលរាជធានីភ្នំពេញ ដែលបានអញ្ជើញចូលរួមក្នុងសន្និសីទសារព័ត៌មាននាពេលនេះ រួមមាន៖

- ខ្ញុំបាទ **ម៉ប់ សារិន** ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ
- ឯកឧត្តម/លោកជំទាវ ........................................................ សមាជិក/សមាជិកាក្រុមប្រឹក្សារាជធានីភ្នំពេញ
- ឯកឧត្តម **គើត ឆែ** អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ
- លោកស្នងការរងនគរបាលរាជធានីភ្នំពេញ លោកនាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ លោកប្រធានមន្ទីរជំនាញ លោក-លោកស្រីនាយកទីចាត់ការ-ប្រធានអង្គភាពពាក់ព័ន្ធ

- និង លោកស្រី ទ្រាក់ ម៉ាលី ចៅសង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង។

## II- អំពីស្ថានភាពភូមិសាស្ត្រ និងក្របខណ្ឌអភិវឌ្ឍន៍រាជធានីភ្នំពេញ

ជាការពិតណាស់ ក្នុងរយៈពេល **៤៣ ឆ្នាំ**កន្លងមកនេះ បន្ទាប់ពីប្រទេសកម្ពុជា បានរួចរំដោះពីរបបប្រល័យពូជសាសន៍ប៉ុលពត ផ្តើមចេញពីថ្ងៃជ័យជម្នះ **០៧ មករា ឆ្នាំ១៩៧៩** និងការដាក់ចេញនូវគោលនយោបាយ "**ឈ្នះ-ឈ្នះ**" របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** មកដល់ពេលបច្ចុប្បន្ននេះ ប្រទេសជាតិយើង ដែលធ្លាប់តែគ្របដណ្តប់ដោយភាពអសន្តិសុខ អស្ថិរភាព ស្នាកស្នាមនៃសង្គ្រាម ភាពក្រីក្រ ឧក្រិដ្ឋកម្ម ការរំលោភសិទ្ធិមនុស្ស និងអំពើប្រល័យពូជសាសន៍ ឥឡូវបានប្រែក្លាយជាប្រទេសប្រកបដោយសន្តិភាព ស្ថិរភាព ការបង្រួបបង្រួមជាតិ ប្រជាធិបតេយ្យ និងមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស ធ្វើឱ្យប្រជាជនទូទាំងប្រទេស រស់នៅប្រកបអាជីវកម្មជាប្រក្រតី និងកំពុងរីករាយទទួលផលពីកំណើនសេដ្ឋកិច្ចប្រមាណ **៧% ក្នុងមួយឆ្នាំ** ដែលយើងទាំងអស់គ្នាបាននឹងកំពុងទទួលបាននូវមនុញ្ញផលនៃសុខសន្តិភាព និងកំពុងប្រើប្រាស់សមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលបានខិតខំពុះពារសម្រេចបានយ៉ាងល្អប្រសើរលើគ្រប់វិស័យ។

សម្រាប់រាជធានីភ្នំពេញ គឺនៅតែរក្សាបាននូវអត្តសញ្ញាណនៃទីក្រុងប្រវត្តិសាស្ត្ររបស់ខ្លួន ដែលជាបេះដូង នៃព្រះរាជាណាចក្រកម្ពុជា និងជាមជ្ឈមណ្ឌលប្រមូលផ្តុំលើគ្រប់វិស័យ រួមមាន វិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច បេតិកភណ្ឌ វប្បធម៌ ទេសចរណ៍ និងការទូត ជាមួយនឹងសន្ទុះនៃការអភិវឌ្ឍយ៉ាងឆាប់រហ័ស។

បន្ថែមលើនេះ នៅក្នុងក្របខ័ណ្ឌនៃការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលជាសកលជំងឺកូវីដ-១៩ នាឆ្នាំ២០២០ និងឆ្នាំ២០២១ កន្លងទៅ តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រគន្លឹះ និងគោលនយោបាយជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនប្រជាជន ស្របតាម "**អភិក្រមផ្កាវីក**" របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** រាជធានីភ្នំពេញ បានក្លាយជាទីក្រុងមួយក្នុងចំណោមប្រទេសក្នុងតំបន់ និងលើពិភពលោក ដែលសម្រេចបានការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនប្រជាជន ក្នុងកម្រិតខ្ពស់ជាងគេ សម្រាប់ជាមូលដ្ឋានគ្រឹះមិនអាចខ្វះបាន ដើម្បីការពារអាយុជីវិតប្រជាជន ខឿនសុខុមាលភាពសាធារណៈ និងការបើកដំណើរការសកម្មភាពសេដ្ឋកិច្ច-សង្គមពេញលេញឡើងវិញលើគ្រប់វិស័យ តាមគន្លងប្រក្រតីភាពថ្មី ចាប់ពី**ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១** និងបានប្រកាសបិទបញ្ចប់ "**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១**" កាលពី**ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១** កន្លងទៅ ប្រកបដោយការទទួលខុសត្រូវខ្ពស់។

ដោយឡែក ចំពោះក្របខ័ណ្ឌនៃការអភិវឌ្ឍ **រដ្ឋបាលរាជធានីភ្នំពេញ** បានអនុវត្តទៅតាមប្លង់គោលប្រើប្រាស់ដីឆ្នាំ ២០៣៥, ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល នៃអាណត្តិក្រុមប្រឹក្សា ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ **(គ.ជ.អ.ប)**, ក្រសួងមហាផ្ទៃ និងក្រសួង-ស្ថាប័នថ្នាក់ជាតិ។

ជារួម នាពេលបច្ចុប្បន្ន ស្ថានភាពគ្រប់គ្រងរដ្ឋបាលដែនដីរបស់រាជធានីភ្នំពេញ គឺចែកចេញជា **១៤ ខណ្ឌ** ស្មើនឹង **១០៥ សង្កាត់** មានប្រជាជនរស់នៅអចិន្ត្រៃយ៍ចំនួន **២,២៨ លាននាក់** និងមានប្រជាជនស្នាក់នៅបម្រើការងារប្រមាណជិត **១លាននាក់**ផ្សេងទៀត ក្នុងអត្រាកំណើន **៣,១៥%** ក្នុងមួយឆ្នាំ និងមានដង់ស៊ីតេប្រមាណ **៣.២៩៥ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ** ហើយភូមិសាស្ត្រដែនដីត្រូវបានពង្រីកព្រំប្រទល់រដ្ឋបាលពី **៣០០** ទៅ **៦៩២,៤៦ គីឡូម៉ែត្រក្រឡា** មានព្រំប្រទល់ភូមិសាស្ត្រហ៊ុំព័ទ្ធដោយខេត្តកណ្តាល គឺ៖

- ខាងកើតទល់នឹងស្រុកកៀនស្វាយ ស្រុកល្វាឯម និងស្រុកខ្សាច់កណ្តាល
- ខាងលិចទល់នឹងស្រុកកណ្តាលស្ទឹង និងស្រុកអង្គស្នួល
- ខាងជើងទល់នឹងស្រុកពញាឮ និងស្រុកមុខកំពូល

- ខាងត្បូងទល់នឹងស្រុកកណ្ដាលស្ទឹង និងក្រុងតាខ្មៅ ។

## III- វឌ្ឍនភាពការងាររបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣

តាមរយៈលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីភ្នំពេញ និងក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ កាលពី **ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩** កន្លងទៅ បេក្ខជនឈរឈ្មោះបោះឆ្នោតមកពីគណបក្សប្រជាជនកម្ពុជា បានទទួលជ័យជម្នះក្នុងការបោះឆ្នោតនេះ ក្នុងនោះ សម្រាប់ក្រុមប្រឹក្សារាជធានីភ្នំពេញ **គណបក្សប្រជាជនកម្ពុជា** ទទួលបានអាសនៈ **២៧/២៧ អាសនៈ** ហើយបន្ទាប់មក នៅ**ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** បានផ្ដល់កិត្តិយសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីប្រកាសចូលកាន់តំណែងរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ ដែលមានសមាសភាព **ប្រធានក្រុមប្រឹក្សា ១ រូប និងសមាជិក-សមាជិកាចំនួន ២៦ រូបផ្សេងទៀតជាសមាជិក។**

គិតចាប់ពីថ្ងៃប្រកាសសុពលភាពចូលកាន់តំណែងជាផ្លូវការ រហូតមកដល់ពេលបច្ចុប្បន្ននេះ ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ បានដំណើរការការងាររបស់ខ្លួនអស់រយៈពេល **២ឆ្នាំ ៨ខែ និង ២ថ្ងៃ** ដោយអនុលោមតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ, ក្របខ័ណ្ឌគតិយុត្ត, បទបញ្ជា និងលិខិតបទដ្ឋានជាធរមាន **ដែលជាលទ្ធផល** ក្រុមប្រឹក្សារាជធានីភ្នំពេញ សម្រេចបានការងារសំខាន់ៗ ដូចខាងក្រោម ៖

- **ទី១៖** បានរៀបចំកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាទៀងទាត់ សរុបបានចំនួន **៣១ លើក,** វិសាមញ្ញ **៣ លើក,** សម្ងាត់ **២ លើក** និងកិច្ចប្រជុំនានារបស់គណៈកម្មាធិការជំនាញ ក្នុងនោះ ក្រុមប្រឹក្សារាជធានីភ្នំពេញ បានចេញដីកាចំនួន **១ ច្បាប់** និងសេចក្ដីសម្រេចចំនួន **៦ ច្បាប់** ដើម្បីធានានិរន្តរភាពការងាររដ្ឋបាលទូទៅ ក្នុងដែនសមត្ថកិច្ច។

- **ទី២៖ ក្រុមប្រឹក្សារាជធានីភ្នំពេញ** បានអនុវត្តយ៉ាងយកចិត្តទុកដាក់នូវគោលនយោបាយ អនុក្រឹត្យ ប្រកាស និងសេចក្ដីណែនាំបច្ចេកទេសនានា ពាក់ព័ន្ធនឹងកិច្ចដំណើរការកសាង និងអនុម័ត**ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ ២០២០-២០២៤ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល** ដើម្បីធានាដល់ការអភិវឌ្ឍមូលដ្ឋាន ដោយមានការចូលរួមពីប្រជាពលរដ្ឋ មន្ទីរ-អង្គភាពជំនាញ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់។ តាមរយៈផែនការទាំងនេះ អនុញ្ញាតឱ្យរដ្ឋបាលរាជធានីភ្នំពេញ អាចបំពេញបេសកកម្មរបស់ខ្លួនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធប្រឡាយ-លូ បណ្ដាញទឹកស្អាត បណ្ដាញអគ្គិសនីសាធារណៈ បណ្ដាញទូរគមនាគមន៍ ការកែលម្អសួនច្បារសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រជាច្រើនទៀត ព្រមទាំងការគិតគូរទុកជាមុនអំពីយន្តការឆ្លើយតបចំពោះគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតកាចសាហាវដែលកំពុងកើតមាន ដូចពេលបច្ចុប្បន្ននេះ។

- **ទី៣៖** បានអនុវត្តគម្រោងសកម្មភាពនៃកម្មវិធីវិនិយោគដែលមានថវិកាគាំទ្រឆ្នាំ២០២១ ក្នុងនោះ រដ្ឋបាលរាជធានីភ្នំពេញ មានគម្រោងសកម្មភាព**ចំនួន ១៤២គម្រោង** និងថវិកា**សរុបចំនួន ៤១៧.០៥១,១៤ លានរៀល (បួនរយដប់ប្រាំពីរពាន់ ហាសិបមួយក្បៀសដប់បួន លានរៀល)**, មន្ទីរ-អង្គភាព ជុំវិញរដ្ឋបាលរាជធានីភ្នំពេញ មានគម្រោងសកម្មភាព **ចំនួន ១០៩គម្រោង** និងថវិកា**សរុប ចំនួន ៩២៩.២៩៧លានរៀល (ប្រាំបួនរយម្ភៃប្រាំបួនពាន់ ពីររយហាសិបប្រាំពីរលានរៀល)**, រដ្ឋបាលខណ្ឌ សង្កាត់ មានគម្រោងសកម្មភាព**ចំនួន ៤២៣គម្រោង** និងថវិកាសរុប**ចំនួន ៥១.៥៣១,២០លានរៀល (ហាសិបមួយពាន់ ប្រាំរយសាមសិបមួយក្បៀសម្ភៃ លានរៀល)**។ ចំណែក កិច្ចលទ្ធកម្មវិញ បានអនុវត្តនីតិវិធីលទ្ធកម្មសរុប **ចំនួន ៩៦គម្រោង** ក្នុងនោះ កិច្ចលទ្ធកម្មទំនិញចំនួន ៣៦គម្រោង និងកិច្ចលទ្ធកម្មសំណង់ចំនួន ៦០គម្រោង ស្មើនឹង ១០០% នៃផែនការលទ្ធកម្មប្រចាំឆ្នាំ២០២១ ហើយបានអនុវត្តកិច្ច លទ្ធកម្មជ្រើសរើសក្រុមហ៊ុនថ្មី ដើម្បីផ្ដល់សេវាប្រមូលសម្អាត និងដឹកជញ្ជូនសំរាម សំណល់រឹង តាមនីតិវិធីដេញថ្លៃប្រកួត ប្រជែងជាអន្តរជាតិ ដោយជ្រើសរើសបានក្រុមហ៊ុនថ្មីដែលមានលក្ខណៈស្តង់ដារចំនួនបី ក្នុងនោះ រួមមាន៖ **(១)** ក្រុមហ៊ុន ៨00 Super **(២)** ក្រុមហ៊ុន Mizuda Group **និង (៣)** ក្រុមហ៊ុន Cintri ហើយក្នុងមួយថ្ងៃជាមធ្យមអាចប្រមូលសំរាមទៅទីលានចាក់សំរាមដង្កោ ប្រមាណ **៣ពាន់តោន** ធ្វើឱ្យលែងមានការកកស្ទះសំរាមនៅតាមដងផ្លូវសាធារណៈ និងរក្សាបាននូវបរិស្ថាន អនាម័យ និងសោភ័ណភាពនៅរាជធានីភ្នំពេញ។

- **ទី៤៖** បានចូលរួមរៀបចំ និងគាំទ្រការដាក់ឱ្យដំណើរការរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលខណ្ឌទាំង១៤ និងការដាក់ឱ្យដំណើរការមន្ទីរសុខាភិបាល ស្ថិតក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានីភ្នំពេញ **ដែលនេះ** គឺជារបត់ថ្មីនៃការកែទម្រង់ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ សំដៅធានាដល់ការផ្ទេរសិទ្ធិ ផ្ទេរអំណាច ផ្ទេរមុខងារ និងធនធាន ដើម្បីបង្កើនការទទួលខុសត្រូវចំពោះការគ្រប់គ្រង

ការចាត់ចែង និងការប្រើប្រាស់សិទ្ធិអំណាច និងធនធាន ទាំងនោះ សម្រាប់ការផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។

- **ទី៥៖** បានខិតខំតម្រង់ទិស និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងដំណើរការអនុវត្តតួនាទី និងភារកិច្ចរបស់**អង្គភាពច្រកចេញ-ចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋរាជធានីភ្នំពេញ** ដើម្បីបង្ខិតសេវាសាធារណៈឱ្យកាន់តែកៀកជិតប្រជាពលរដ្ឋ។ គិតចាប់ពីពេលបើកដំណើរការរហូតមកដល់ពេលនេះ **អង្គភាពច្រកចេញ-ចូលតែមួយរាជធានីភ្នំពេញ** បានផ្តល់សេវាជូនប្រជាពលរដ្ឋសរុបចំនួន **១៩៥.៨២៨ សេវា (ដប់ប្រាំម៉ឺន ប្រាំពាន់ប្រាំបីរយម្ភៃប្រាំបីសេវា)** ដោយទទួលបានចំណូលបង់ចូលថវិការដ្ឋសរុបចំនួន **៤៤.៣៦៨.៥០១.២៥០រ (សែសិបបួនពាន់ បីរយហុកសិបប្រាំបីលាន ប្រាំសែនមួយពាន់ ពីររយហាសិបរៀល)** គឺប្រមាណ **ជាង ១១ លានដុល្លាអាមេរិក**។ ដោយឡែក ចំពោះដំណើរការការងាររបស់**ការិយាល័យប្រជាពលរដ្ឋរាជធានីភ្នំពេញ** នៅមានបញ្ហាប្រឈមមួយចំនួន ដោយហេតុថា ការិយាល័យនេះគឺជាយន្តការថ្មីជួបផ្ទុំមានផលរំខានខ្លះៗនៃការរីករាលដាលជំងឺកូវីដ-១៩ **ដូច្នេះ** ការិយាល័យនេះ ចាំបាច់ត្រូវមានការផ្សព្វផ្សាយអំពីតួនាទីភារកិច្ច ឱ្យបានទូលំទូលាយ និងត្រូវពង្រឹងប្រសិទ្ធភាពដឹកនាំបន្ថែមទៀត។

- **ទី៦៖** សម្រាប់ការពង្រឹងគណនេយ្យភាពសង្គម ក្រៅអំពីគេហទំព័រផ្លូវការរបស់រដ្ឋបាលរាជធានីភ្នំពេញ សម្រាប់ទទួលយកនូវមតិយោបល់ពីសាធារណជនតាមប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គម **រដ្ឋបាលរាជធានីភ្នំពេញ** បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ នៅតាមបណ្តាខណ្ឌទូទាំងរាជធានីភ្នំពេញ រៀងរាល់ត្រីមាសទី៤ នៃឆ្នាំនីមួយៗ ក្នុងនោះ នៅ**ឆ្នាំ២០១៩** វេទិកានេះមានប្រជាពលរដ្ឋចូលរួមសរុបចំនួន **៧.៨៥៥ នាក់** ដោយទទួលបានសំណួរ-សំណើ-សំណូមពរទាំងផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរចំនួន **១.២៨៣ ករណី** និងនៅ**ឆ្នាំ២០២០** វេទិកានេះមានប្រជាពលរដ្ឋចូលរួមសរុបចំនួន **៤.៣០៥ នាក់** (ថយចុះជិតពាក់កណ្តាល ដោយសារយើងត្រូវរក្សាគម្លាតសុវត្ថិភាព និងអនុវត្តវិធានសុខាភិបាល) ដោយទទួលបានសំណួរ-សំណើ-សំណូមពរទាំងផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរចំនួន **៩៥៥ ករណី**។ ដោយឡែក ក្នុង**ឆ្នាំ២០២១** នេះ ក្រុមប្រឹក្សារាជធានីភ្នំពេញ ក៏ដូចជាក្រុមប្រឹក្សាគ្រប់ថ្នាក់ មិនទាន់បានរៀបចំវេទិកានេះទេ ដោយត្រូវពន្យារពេលអាស្រ័យលើស្ថានភាពនៃការរាតត្បាតជំងឺកូវីដ-១៩ ស្របតាមខ្លឹមសារនៃលិខិតលេខ **១៥២២ សជណ** ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ។ ជាការកត់សម្គាល់ តាមរយៈវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ បានបង្កើតឱកាសឱ្យមានការជួបពិភាក្សារវាងក្រុមការងារថ្នាក់ជាតិ ក្រុមប្រឹក្សារដ្ឋបាលគ្រប់ជាន់ថ្នាក់ ជាមួយនឹងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ច ដើម្បីទទួលបាននូវមតិយោបល់ ការព្រួយបារម្ភ និងសំណើសំណូមពរនានាក្នុងមូលដ្ឋាន **ដែលជាលទ្ធផល** សំណួរ-សំណើ-សំណូមពរមួយចំនួន ត្រូវបានដោះស្រាយជូនភ្លាមៗក្នុងអង្គវេទិកា, មួយចំនួនទៀតត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងសំណួរ-សំណើ-សំណូមពរខ្លះទៀត ដែលលើសពីសមត្ថកិច្ចដោះស្រាយ ត្រូវបានរដ្ឋបាលរាជធានីភ្នំពេញយកចិត្តទុកដាក់អន្តរាគមន៍ស្នើសុំទៅក្រសួង-ស្ថាប័នជំនាញ ដើម្បីពិនិត្យលទ្ធភាពដោះស្រាយជូនជាបន្តបន្ទាប់។

- **ទី៧៖** បន្ថែមលើនេះ ស្ថិតក្នុងដំណាក់កាលនៃការរីករាលដាលជាសកលជំងឺកូវីដ-១៩ **ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣** បានផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់គណៈអភិបាលរាជធានីភ្នំពេញ ក្នុងការអនុវត្តច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ជាពិសេសយុទ្ធសាស្ត្រគន្លឹះ និងវិធានការដ៏មុតស្រួចរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលធ្វើឱ្យស្ថានភាពនៃការគ្រប់គ្រងការរីករាលដាលជំងឺកូវីដ-១៩ កំពុងឈានទៅរកភាពល្អ ប្រសើរឡើង ហើយរាជធានីភ្នំពេញ ត្រូវបានគេទទួលស្គាល់ថាជាទីក្រុងដែលបានចាក់ស្រោចវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនដល់ប្រជាពលរដ្ឋច្រើនជាងគេក្នុងពិភពលោក ដែលមានអត្រាគ្របដណ្តប់ស្ទើរតែ ១00% និងកំពុងស្ថិតក្នុងគន្លងប្រក្រតីភាពថ្មី នៃការបើកដំណើរការសេដ្ឋកិច្ច-សង្គមឡើងវិញលើគ្រប់វិស័យ។ **គិតត្រឹមថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២២** ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នៅរាជធានីភ្នំពេញ សម្រេចបានលទ្ធផល ដូចខាងក្រោម ៖

+ **ប្រជាពលរដ្ឋអាយុចាប់ពី ១៨ឆ្នាំឡើងទៅ** ៖ ដូសមូលដ្ឋានសរុប **១.៧០៩.៣៦៨ នាក់** ស្មើនឹង **១២១%** ដូសជំរុញ (ដូសទី៣) សរុប **១.២៨១.៥០១ នាក់** ស្មើនឹង **៩០,៧%** និងដូសជំរុញ (ដូសទី៤) សរុប **៥២២.៦៦៩ នាក់** ស្មើនឹង **៣៧%**
+ **កុមារអាយុចាប់ពី១២ឆ្នាំ ដល់ក្រោម១៨ឆ្នាំ** ៖ ដូសមូលដ្ឋានសរុប **២២០.៩៦៣ នាក់** ស្មើនឹង **១១៥,៤%** និងដូសជំរុញ (ដូសទី៣) សរុប **១៤៥.២៤៦ នាក់** ស្មើនឹង **៧៥,៩%**
+ **កុមារអាយុចាប់ពី៦ឆ្នាំ ដល់ក្រោម១២ឆ្នាំ** ៖ ដូសមូលដ្ឋានសរុប **២៣៩.៨១២ នាក់** ស្មើនឹង **១០៨,៥%** និងដូសជំរុញ (ដូសទី៣) សរុប **៣០.៧៧៩ នាក់** ស្មើនឹង **១៤%**
+ **កុមារអាយុ៥ឆ្នាំ** ៖ ដូសទី១ សរុប **៥៧.៩១៦ នាក់** ស្មើនឹង **១១៦,២%** និងដូសទី២ សរុប **៤៤.៩៨៨ នាក់** ស្មើនឹង **៩០,៣%**
+ **និង កំពុងបើកយុទ្ធនាការចាក់វ៉ាក់សាំងជូនកុមារអាយុពី ៣ ឆ្នាំ ដល់ក្រោម ៥ឆ្នាំ បន្ថែមទៀត។**

## IV- អំពីទិសដៅការងារបន្តរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ

ចំពោះទិសដៅការងារបន្តរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ មានដូចខាងក្រោម៖

- **ទី១៖ ការងារចំពោះមុខ** គឺបន្តចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្ការ ទប់ស្កាត់ និងគ្រប់គ្រងស្ថានភាពការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេស មេរោគបំប្លែងខ្លួនថ្មី ប្រភេទ **"អូមីក្រុង"** ដែលកំពុងចរាចរណ៍យ៉ាងសកម្មក្នុងសហគមន៍ តាមរយៈការដាក់ចេញចំណាត់ការ ស្របតាមការណែនាំនានារបស់រាជរដ្ឋាភិបាលកម្ពុជា រួមមាន៖

+ បន្តយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនកុមារអាយុចាប់ពី ៣ឆ្នាំឡើងទៅ និងប្រជាពលរដ្ឋទូទៅ ទាំងដូសមូលដ្ឋាន ដូសជំរុញ និងដូសបន្តបន្ទាប់ សំដៅបង្កើនភាពស៊ាំសហគមន៍រឹងមាំទប់ទល់នឹងជំងឺកូវីដ-១៩
+ បន្តជំរុញអាជ្ញាធរមូលដ្ឋាន និងមន្ទីរជំនាញពាក់ព័ន្ធ ឱ្យអនុវត្តតួនាទី-ភារកិច្ចរបស់ខ្លួន ឱ្យបានល្អប្រសើរ ដូចជា ការពង្រឹងការផ្តល់សេវាសាធារណៈក្នុងដែនសមត្ថកិច្ច ការពង្រឹងការងារចាក់វ៉ាក់សាំង ការងារព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ ការងារចុះត្រួតពិនិត្យការអនុវត្តវិធានការសុខាភិបាលនៅតាមទីតាំងអាជីវកម្មដ្ឋានគ្រប់ប្រភេទ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន រោងចក្រ-សហគ្រាស ជាដើម និងការរក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងមូលដ្ឋាន
+ អប់រំ ណែនាំ ផ្សព្វផ្សាយ និងក្រើនរំលឹកដល់ប្រជាពលរដ្ឋ ឱ្យបង្កើនការប្រុងប្រយ័ត្នខ្ពស់ និងបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការសុខាភិបាល និងវិធានការ **"៣ការពារ និង ៣កុំ"** របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
+ បន្តពង្រឹងការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ ចំពោះបុគ្គលទាំងឡាយណា ដែលប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងវិធានការសុខាភិបាល
+ បន្តកិច្ចសហការជាមួយក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខណ្ឌទាំង ១៤ ដើម្បីគាំទ្រផ្នែកជីវភាពរស់នៅដល់បងប្អូនប្រជាពលរដ្ឋក្នុងសហគមន៍ ដែលកំពុងប្រឈមនឹងកង្វះខាតស្បៀងអាហារ ស្របតាមអនុសាសន៍របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលបានលើកឡើងថា **"មិនត្រូវទុកឱ្យប្រជាពលរដ្ឋណាម្នាក់ស្លាប់ដោយដាច់បាយឡើយ"** ។

- **ទី២៖** បន្តពង្រឹងតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររវាងក្រុមប្រឹក្សា និងគណៈអភិបាលរាជធានីភ្នំពេញ ឱ្យស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន សំដៅធានាដល់ការគាំទ្រ ការជំរុញ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅមូលដ្ឋាន ឱ្យមានការរីកចម្រើន។

- **ទី៣៖** បន្តបង្កើនការយកចិត្តទុកដាក់អនុវត្តគោលនយោបាយ **"ភូមិ-សង្កាត់ មានសុវត្ថិភាព"** ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ជាពិសេសជំរុញការអនុវត្តយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់

លើកទី៧ របស់រាជរដ្ឋាភិបាលកម្ពុជា ឱ្យសម្រេចបានលទ្ធផលល្អ ក្នុងន័យធ្វើយ៉ាងណាថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពជូនប្រជាពលរដ្ឋ។ ជាមួយគ្នានេះ ត្រូវបន្តពង្រឹងការអនុវត្តច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ឱ្យបានផុលផុស និងជាប់ជាប្រចាំ ដើម្បីកាត់បន្ថយ និងការពារអាយុជីវិតអ្នកបើកបរ និងប្រជាពលរដ្ឋ ពីគ្រោះថ្នាក់ចរាចរណ៍។

- **ទី៤៖** បន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ នៅតាមបណ្ដាមូលដ្ឋានខណ្ឌទាំង ១៤ ដើម្បីបង្កើតឱកាសឱ្យមានការជួបពិភាក្សារវាងក្រុមការងារថ្នាក់ជាតិ ក្រុមប្រឹក្សារដ្ឋបាលគ្រប់ជាន់ថ្នាក់ជាមួយនឹងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ច ដើម្បីទទួលបាននូវមតិយោបល់ ការព្រួយបារម្ភ និងសំណើសំណូមពរនានាក្នុងមូលដ្ឋាន សំដៅធានាសុខុមាលភាពការរស់នៅរបស់ប្រជាពលរដ្ឋ ឱ្យកាន់តែប្រសើរឡើង។

- **ទី៥៖** បន្តជំរុញការផ្ដល់សេវាសាធារណៈតាម **អង្គភាពច្រកចេញចូលតែមួយរាជធានីភ្នំពេញ ការិយាល័យច្រកចេញចូលតែមួយខណ្ឌ និងយន្តការច្រកចេញចូលតែមួយសង្កាត់** ឱ្យបានល្អប្រសើរជូនប្រជាពលរដ្ឋ ដើម្បីចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងចូលរួមលើកកម្ពស់ការអនុវត្តកំណែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាព។

- **ទី៦៖** បន្តពង្រឹងតួនាទី និងភារកិច្ចរបស់ **ការិយាល័យប្រជាពលរដ្ឋរាជធានីភ្នំពេញ** ដើម្បីចូលរួមលើកកម្ពស់អភិបាលកិច្ចល្អក្នុងការផ្ដល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការទទួល និងសម្រុះសម្រួលដោះស្រាយបណ្ដឹងនៅក្រៅប្រព័ន្ធតុលាការ ដែលពាក់ព័ន្ធនឹងការផ្ដល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព សំដៅបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

- **ទី៧៖** បន្តពង្រឹងការងារគ្រប់គ្រងសំរាម និងសំណល់រឹងគ្រប់ប្រភេទក្នុងរាជធានីភ្នំពេញ តាមរយៈការពង្រឹងសមត្ថភាពរបស់ **រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ** ដែលបានប្រែក្លាយខ្លួនពី **អ្នកគ្រប់គ្រងសេវា** ទៅជា **ប្រតិបត្តិករផ្ដល់សេវា**។ តាមរយៈនេះ យើងត្រូវបន្តពិនិត្យ និងណែនាំជាប្រចាំចំពោះក្រុមហ៊ុនដែលអនុវត្តការងារ ប្រមូលសម្អាតសំរាម ដើម្បីធានាពីគុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវា ព្រមទាំងដើម្បីធានាពីសោភណភាព ទីក្រុងរបស់យើង។

- **ទី៨៖** បន្តពង្រឹងការគ្រប់គ្រង និងបណ្ដុះបណ្ដាលធនធានមនុស្ស តាមរយៈ **ការពង្រឹងសមត្ថភាពមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានីភ្នំពេញ** ដែលបានបង្កើតឡើងតាមការណែនាំរបស់ក្រសួងមហាផ្ទៃ ដើម្បីឱ្យមន្ត្រីរាជការ និងបុគ្គលិកក្រោមឱវាទរដ្ឋបាលរាជធានីភ្នំពេញ មានសមត្ថភាព និងចំណេះដឹងរឹងមាំទាំងផ្នែកគ្រប់គ្រងរដ្ឋបាលដែនដី និងផ្នែកគ្រប់គ្រងបុគ្គលិក ក្នុងនោះ ត្រូវបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ ដើម្បីចាត់បញ្ជូនមន្ត្រីរាជការ និងបុគ្គលិកក្រោមឱវាទ ទៅចូលរួមក្នុងវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា ឬ កិច្ចប្រជុំនានា សមស្របទៅនឹងជំនាញវិជ្ជាជីវៈ។

- **ទី៩៖** បន្តជំរុញ និងគាំទ្រការអនុវត្តក្របខណ្ឌការងារគណនេយ្យភាពសង្គម និងគេហទំព័រផ្លូវការរបស់រដ្ឋបាលរាជធានីភ្នំពេញ សម្រាប់ទទួលយកនូវមតិយោបល់ពីសាធារណជនតាមប្រព័ន្ធបណ្ដាញទំនាក់ទំនងសង្គម និងដោះស្រាយជូនពួកគាត់ឱ្យទាន់ពេលវេលា ឆាប់រហ័ស តម្លាភាព ប្រសិទ្ធភាព ភាពជឿទុកចិត្ត និងគណនេយ្យភាពខ្ពស់។

- **ទី១០៖** បន្តដឹកនាំ និងតម្រង់ទិសរដ្ឋបាលខណ្ឌ មន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលសង្កាត់ត្រូវអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ឱ្យបានល្អប្រសើរ ស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ សំដៅជំរុញ និងលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងពង្រឹងការអនុវត្តគោល-ការណ៍ **រដ្ឋបាលឯកភាព** ឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។

- **ទី១១៖** បន្តជំរុញ ណែនាំ និងតម្រង់ទិសដល់ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់ ដើម្បីត្រៀមលក្ខណៈក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាសង្កាត់ អាណត្តិទី៦ ឆ្នាំ២០២២ ខាងមុខនេះ ឱ្យប្រព្រឹត្តទៅក្នុងបរិយាកាស **សេរី ត្រឹមត្រូវ និងយុត្តិធម៌** ដូចអ្វីដែលយើងបានអនុវត្តនាពេលកន្លងមក។

## V- អំពីយន្តការនៃការអនុវត្តការងាររបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់មូលដ្ឋានសង្កាត់ ក្នុងរាជធានីភ្នំពេញ

ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់មូលដ្ឋានសង្កាត់ ក្នុងរាជធានីភ្នំពេញ **ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣** បានអនុវត្តការងារតាមរយៈអង្គភាពជាសេនាធិការ ដែលត្រូវបានបង្កើតឡើង ដូចខាងក្រោម ៖

**១- ការសម្របសម្រួល និងគាំទ្រពីគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ រួមមាន៖**

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការលទ្ធកម្ម
- គណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការរៀបចំគម្រោងរាជធានីភ្នំពេញ
- គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មរាជធានីភ្នំពេញ
- គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស និងក្រុមការងារបច្ចេកទេសនៃមណ្ឌលអភិវឌ្ឍន៍ធនធានធានមនុស្សរាជធានីភ្នំពេញ

**២- ការសម្របសម្រួល និងគាំទ្រពីទីចាត់ការ និងអង្គភាពជំនាញក្រោមចំណុះរដ្ឋបាលរាជធានីភ្នំពេញ រួមមាន៖**

- ទីចាត់ការរដ្ឋបាល
- ទីចាត់ការផែនការ និងវិនិយោគ
- ទីចាត់ការហិរញ្ញវត្ថុ
- ទីចាត់ការរៀបចំក្រុង
- ទីចាត់ការគ្រប់គ្រងធនធានមនុស្ស
- ទីចាត់ការអន្តរវិស័យ
- ទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស
- ទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន
- ទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
- អង្គភាពលទ្ធកម្ម
- អង្គភាពច្រកចេញចូលតែមួយរាជធានីភ្នំពេញ
- ការិយាល័យប្រជាពលរដ្ឋរាជធានីភ្នំពេញ
- រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង
- រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ
- មន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានីភ្នំពេញ។

**ក្រៅពីយន្តការខាងលើ យើងនៅមានយន្តការសំខាន់ផ្សេងទៀត ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់មូលដ្ឋានសង្កាត់ ក្នុងរាជធានីភ្នំពេញ ក្រុមប្រឹក្សារាជធានីភ្នំពេញ ត្រូវអនុវត្ត យន្តការទំនាក់ទំនងអន្តររដ្ឋបាល ដូចខាងក្រោម ៖**

- **ទី១៖** ពិគ្រោះយោបល់ និងផ្តល់ការគាំទ្រក្រុមប្រឹក្សាខណ្ឌ ឬ សង្កាត់ដែលពាក់ព័ន្ធ ដើម្បីលើកកម្ពស់សមត្ថភាពក្នុងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្ម ឬ ផ្ទេរជូន
- **ទី២៖** ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខណ្ឌ និងសង្កាត់ ដើម្បីដាក់បញ្ចូលយុទ្ធសាស្ត្រ កម្មវិធី និងសកម្មភាពសម្រាប់ឆ្លើយតបតម្រូវការ និងសំណើរបស់ក្រុមប្រឹក្សាខណ្ឌ និង/ឬ ក្រុមប្រឹក្សាសង្កាត់ ទៅក្នុងផែនការអភិវឌ្ឍន៍

រយៈពេល ៥ឆ្នាំ របស់ក្រុមប្រឹក្សារាជធានី និងរបស់ក្រុមប្រឹក្សាខណ្ឌ សង្កាត់ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលរបស់ក្រុមប្រឹក្សារាជធានី និងរបស់ក្រុមប្រឹក្សាខណ្ឌ សង្កាត់

- **<u>ទី៣៖</u>** ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខណ្ឌ ឬ សង្កាត់ ដើម្បីរៀបចំដាក់បញ្ចូល និងឆ្លុះបញ្ចាំងទៅវិញទៅមក នូវគម្រោងថវិកាប្រចាំឆ្នាំ និងក្របខណ្ឌចំណាយរយៈពេលមធ្យមរបស់ក្រុមប្រឹក្សារាជធានី និងរបស់ក្រុមប្រឹក្សាខណ្ឌ ឬ សង្កាត់ក្នុងរាជធានី ស្របតាមបែបបទនីតិវិធីនៃការរៀបចំថវិកាប្រចាំឆ្នាំ និងការរៀបចំក្របខណ្ឌចំណាយរយៈពេលមធ្យមរបស់រាជធានី ខណ្ឌ និងសង្កាត់ក្នុងរាជធានីភ្នំពេញ
- **<u>ទី៤៖</u>** ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខណ្ឌ ឬ សង្កាត់ក្នុងរាជធានីភ្នំពេញ សំដៅធានាឱ្យបានថា ជម្រើស សេចក្តីសម្រេច និងសកម្មភាពរបស់ក្រុមប្រឹក្សាខណ្ឌ ឬ សង្កាត់ មានការឆ្លើយតបចំពោះតម្រូវការជាអាទិភាពរបស់ក្រុមប្រឹក្សាខណ្ឌ ឬ សង្កាត់ក្នុងរាជធានី និងប្រជាពលរដ្ឋទាំងអស់ក្នុងរាជធានី។ **ចំណែកក្រុមប្រឹក្សាសង្កាត់** ត្រូវផ្តល់យោបល់ ពិគ្រោះយោបល់ និងត្រួតពិនិត្យលើជម្រើសអាទិភាពរបស់ក្រុមប្រឹក្សារាជធានី ដែលបានដាក់ចេញ ថាតើនៅតែឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋដែរឬទេ។ ជាមួយគ្នានេះ ត្រូវលើកសំណូមពរដល់ក្រុមប្រឹក្សារាជធានី និងខណ្ឌអំពីតម្រូវការនានារបស់ប្រជាពលរដ្ឋ ដែលខ្លួនមិនអាចដោះស្រាយបានដោយសមត្ថភាព ឬ ដោយធនធានរបស់ខ្លួន ព្រមទាំងត្រូវធ្វើកិច្ចសហប្រតិបត្តិការ ឱ្យបានពេញលេញ ជាមួយក្រុមប្រឹក្សារាជធានី និងក្រុមប្រឹក្សាខណ្ឌ ដើម្បីលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍន៍នៅមូលដ្ឋាន
- **<u>ទី៥៖</u>** ណែនាំដល់ក្រុមប្រឹក្សាខណ្ឌ សង្កាត់ អំពីការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ឱ្យស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀតជាធរមាន សំដៅធានាដល់ការអនុវត្តភារកិច្ចប្រចាំថ្ងៃរបស់សង្កាត់ ឱ្យប្រព្រឹត្តទៅដោយរលូន និងអភិវឌ្ឍចំគោលដៅ ដែលបានដាក់ចេញក្នុងផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលរបស់ខ្លួន
- **<u>ទី៦៖</u>** ផ្តល់ការគាំទ្រ ការសម្របសម្រួល និងការធ្វើសហប្រតិបត្តិការជាមួយរដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ ដើម្បីរួមគ្នាសម្រេចឱ្យបាននូវគោលនយោបាយរបស់ជាតិ តាមរយៈការទទួលបាននូវប្រតិភូកម្មពីរាជរដ្ឋាភិបាល
- **<u>ទី៧៖</u>** ធ្វើការត្រួតពិនិត្យនីត្យានុកូលភាពនៃការអនុវត្តមុខងារ ភារកិច្ចដែលបានធ្វើប្រតិភូកម្មឱ្យខណ្ឌ និងសង្កាត់ ដើម្បីធានាថា ខណ្ឌ និងសង្កាត់អនុវត្តមុខងារ ភារកិច្ចទាំងនេះ ក្នុងក្របខណ្ឌនៃការងារដែលបានធ្វើប្រតិភូកម្មឱ្យលើមូលដ្ឋាននៃការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងធានាថា ខណ្ឌ និងសង្កាត់ឆ្លើយតបបានយ៉ាងប្រសើរបំផុតនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ
- **<u>ទី៨៖</u>** ណែនាំ ជំរុញ គាំទ្រ និងតម្រង់ទិសដល់ក្រុមប្រឹក្សាសង្កាត់ តាមរយៈការពង្រឹងសមត្ថភាពរដ្ឋបាលសង្កាត់ ទាំងធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងមធ្យោបាយ-សម្ភារផ្សេងៗ នៅក្នុងក្របខណ្ឌផ្នែករដ្ឋបាល និងការពង្រឹងសមត្ថភាពការិយាល័យរៀបចំការបោះឆ្នោតសង្កាត់ ឱ្យបានយល់ដឹងទូលំទូលាយអំពីច្បាប់ បែបបទ និងនីតិវិធីនៃការចុះបញ្ជីឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត និងដំណើរការនៃការបោះឆ្នោត ដើម្បីទទួលបានការឈ្នះឆ្នោតជ្រើសរើសក្រុមប្រឹក្សាសង្កាត់ អាណត្តិទី៦ ឆ្នាំ២០២២ ខាងមុខ
- **<u>ទី៩៖</u>** សម្របសម្រួល និងសហការជាមួយក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខណ្ឌទាំង ១៤ ក្នុងរាជធានីភ្នំពេញ ដើម្បីគាំទ្រផ្នែកជីវភាពរស់នៅដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ តាមរយៈការបង្កិតសេវាសាធារណៈជូនប្រជាពលរដ្ឋ ការលើកកម្ពស់សេវាសុខុមាលភាព និងសេវាសង្គម ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅមូលដ្ឋាន ការផ្តល់ឱកាសឱ្យមានការចូលរួម ការលើកកម្ពស់ និងដោះស្រាយសំណើ-សំណូមពរ-បញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

*៧- ទាំងអស់នេះ គឺជាវឌ្ឍនភាព និងទិសដៅការងារសំខាន់ៗ របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ ព្រមទាំងយន្តការនៃការអនុវត្តការងាររបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់មូលដ្ឋានសង្កាត់ ក្នុងរាជធានីភ្នំពេញ ដែលខ្ញុំបាទសូមគោរពរាយការណ៍ជូនបងប្អូនប្រជាពលរដ្ឋ និងសាធារណៈជន មេត្តាជ្រាបជារបាយការណ៍*

*ដ៏ខ្ពង់ខ្ពស់។ ខ្ញុំសូមបញ្ចប់សេចក្តីរាយការណ៍របស់ខ្ញុំត្រឹមតែប៉ុណ្ណោះ ដើម្បីទុកពេលវេលាជូនសហការីរបស់ខ្ញុំ បានចូលរួមផ្តល់នូវព័ត៌មានបំពេញបន្ថែម និងសូមប្រគល់វេទិកានេះជូន* ***ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល*** *ដើម្បីដឹកនាំសម្របសម្រួលកម្មវិធីបន្ត។* ***សូមអរគុណ !***

………………………………………………………………

**កម្មវិធីសំណួរ-ចម្លើយ៖**

………………………………………………………………

……………………………………………………………

## ការថ្លែងអំណរគុណបញ្ចប់កម្មវិធីៈ

……………………………………………………………

៨- ជាទីបញ្ចប់ ក្នុងនាមរដ្ឋបាលរាជធានីភ្នំពេញ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ **ខ្ញុំព្រះករុណាខ្ញុំ** សូមប្រគេនពរ **សម្តេចព្រះសង្ឃនាយកនាំងពីរគណៈ ព្រមទាំងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ** សូមប្រកបដោយព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីដឹកនាំ និងគង់ជាម្លប់សម្រាប់ពុទ្ធសាសនិកជនកម្ពុជាគ្រប់រូប ឱ្យបន្តទ្រទ្រង់វិស័យព្រះពុទ្ធសាសនា បានគង់វង្សស្ថិតស្ថេរជានិច្ចនិរន្តរ៍។

៩- ជាមួយគ្នានេះ **ទូលព្រះបង្គំ** សូមព្រះបរមរាជានុញ្ញាតជាថ្មីម្តងទៀត លើកហត្ថប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឫទ្ធិបារមីទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ សូមជួយបីបាច់ថែរក្សា អភិបាលប្រោះព្រំព្រះសព្ទសាធុការពរជ័យគ្រប់ប្រការ ថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី និង សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** សូមទ្រង់ប្រកបដោយព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ព្រះសុខុមាលភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ដើម្បីបានគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ក្សេមក្សាន្ត នៃកូនចៅ និងប្រជារាស្ត្ររបស់ព្រះអង្គ យូរអង្វែងជានិរន្តរ៍រៀងទៅ។

១០- សូមគោរពជូនពរបវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការជូន **សម្តេចប្រធានព្រឹទ្ធសភា, សម្តេចប្រធានរដ្ឋសភា, សម្តេចតេជោនាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំង **សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី** សូមបានប្រកបនូវសុខភាពល្អបរិបូរណ៍ អាយុយឺនយូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីបន្តដឹកនាំ និងអភិវឌ្ឍមាតុភូមិកម្ពុជា ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមបម្រើជាតិ និងប្រជាជនកម្ពុជា ឱ្យកាន់តែរីកចម្រើនឈានឆ្ពោះទៅរកភាពសំបូរសប្បាយ រុងរឿងចិរកាល។

១១- សូមប្រសិទ្ធពរជ័យជូន **សម្តេច ទ្រង់ ឯកឧត្តម-លោកជំទាវ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងសហការី** ព្រមទាំងឯកឧត្តម-លោកជំទាវ លោក-លោកស្រី មន្ត្រីរាជការ អ្នកសារព័ត៌មាន បងប្អូនប្រជាពលរដ្ឋ និងទស្សនិកជនដែលកំពុងទស្សនាការផ្សាយបន្តផ្ទាល់ទាំងអស់ សូមបានសមប្រកបដោយព្រះពុទ្ធពរទាំង **៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ** និងចៀសឆ្ងាយផុតពីជំងឺកូវីដ-១៩ កុំបីឃ្លៀងឃ្លាតឡើយ៕

**សូមអរគុណ !**